# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១_អនុក្រឹត្យ

*រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦*

**អនុក្រឹត្យលេខ ៥២ អនក្រ.បក**

**ស្តីពីការបង្កើត**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**(រ.ទ.ស.ភ)**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈ ទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

## សំរេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ( **រ.ឧ.ស.ភ**) ជាគ្រឹះស្ថានសាធារណៈមួយមានឧបនិស្ស័យសេដ្ឋកិច្ចតាមន័យរបស់មាត្រា២៦ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ **រ.ឧ.ស.ភ**ជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**រ.ឧ.ស.ភ** ស្ថិតនៅក្រោមអាណាព្យាបាលនៃសាលាក្រុងភ្នំពេញ ហើយមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

**រ.ឧ.ស.ភ** ត្រូវស្ថិតនៅក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយក្នុងករណីដែល អនុក្រឹត្យនេះពុំបានបញ្ជាក់ការគ្រប់គ្រងនៃ **រ.ឧ.ស.ភ** ត្រូវគោរពតាមបទបញ្ញត្តិ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ព្រមទាំងតាមបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា ២ :** **រ.ឧ.ស.ភ** មានបេសកកម្ម ផលិត និង ចែកចាយទឹក សំរាប់ការប្រើប្រាស់ទូទៅនៃសាធារណជននៅទីក្រុងភ្នំពេញ ។

ដើម្បីបំពេញបេសកកម្មនេះ **រ.ឧ.ស.ភ** ត្រូវអនុញ្ញាតអោយធ្វើកិច្ចប្រតិបត្តិការគ្រប់ជំពូក លើអចលនវត្ថុ ព្រមទាំងផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាអាទិ៍ ÷

- ការផលិត និងការចែកចាយទឹកទូទៅក្នុងរាជធានីភ្នំពេញ ឬ នៅទីប្រជុំជនជុំវិញទីក្រុង ភ្នំពេញ ។

-ការពង្រីក ការបង្កើន និងការស្តារឡើងវិញនូវប្រព័ន្ធផលិត និងបណ្តាញចែកចាយទឹក

-ការធ្វើអាជីវកម្មលើបណ្តាញចែកចាយទឹក ដែលមានស្រាប់ ឬ ដែលត្រូវបង្កើត ។

**មាត្រា ៣ :** ភ្នាក់ងារ **រ.ឧ.ស.ត** មានសិទ្ធិចេញចូលក្នុងទីកន្លែងសាធារណៈ ឬ ទីលំនៅឯកជនតាមតំរូវការងាររបស់ខ្លួនជាអាទិ៍ ដើម្បីធ្វើការតំឡើង និងជួសជុលបំពង់ទឹកការត្រួតពិនិត្យផ្នែកបច្ចេកទេស គ្រឿងម៉ាស៊ីនផលិតកម្ម និងបណ្តាញចែកចាយទឹកហើយនឹងការកត់ស្រង់នូវបរិមាណទឹកដែលបានប្រើប្រាស់ ។

ភ្នាក់ងារ **រ.ឧ.ស.ត** ទាំងនេះត្រូវមានសំលៀកបំពាក់សំគាល់ និងត្រូវកាន់ប័ណ្ណអាជីវកម្ម យថាភូតភ្ជាប់នឹងខ្លួន ។

**មាត្រា ៤ :** ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន **រ.ឧ.ស.ត** ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នា នឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ **រ.ឧ.ស.ត** ត្រូវទទួលស្វ័យតភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មរបស់ខ្លួនអោយមានប្រសិទ្ធភាព និងធ្វើយ៉ាងណាអោយបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

**មាត្រា ៥ :** **រ.ឧ.ស.ត** ត្រូវបង់ពន្ធអាករទាំងឡាយ ស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ :** ដើមទុនដំបូងរបស់ **រ.ឧ.ស.ត** ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ សាលាក្រុងភ្នំពេញ និង **រ.ឧ.ស.ត** ។

ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន **រ.ឧ.ស.ត** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ ដែលមានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ :** បុគ្គលិករបស់ **រ.ឧ.ស.ត** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ទំរាំមានលក្ខន្តិកៈដោយឡែកនេះ ក្រុមប្រឹក្សាភិបាល **រ.ឧ.ស.ត** នឹងសំរេចអំពីអន្តរវិធាន ដែលទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន ដើម្បីអោយសហគ្រាសអាចមានដំណើរការប្រព្រឹត្តទៅប្រកបដោយសមស្រប ។

ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែក នេះចូលជាធរមាន បុគ្គលិករបស់ **រ.ឧ.ស.ត** លែងមានលក្ខណសម្បត្តិជាមន្ត្រីរាជការរបស់រដ្ឋតទៅទៀត ។

## **ជំពូកទី២**

## **រចនាសម្ព័ន្ធវិស័យរដ្ឋបាល**

**មាត្រា ៨ :** **រ.ឧ.ស.ត** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិកដូចខាងក្រោមនេះ ÷

- តំណាងសាលាក្រុងភ្នំពេញ ...... ១ រូប
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ...... ១ រូប
- តំណាងក្រសួងមហាផ្ទៃ ...... ១ រូប
- តំណាងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ...... ១ រូប
- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ...... ១ រូប
- តំណាងនិយោជិករបស់ **រ.ឧ.ស.ត** ...... ១ រូប
- អគ្គនាយក **រ.ឧ.ស.ត** ...... ១ រូប

តំណាងសាលាក្រុងភ្នំពេញមានមុខងារជាប្រធាននៃក្រុមប្រឹក្សាភិបាល ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវចាត់តែងតាំងដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងអោយ ។

តំណាងនិយោជិកត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិករបស់ **រ.ឧ.ស.ត** ។

**មាត្រា ៩ :** សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានសញ្ជាតិជាខ្មែរ មានសិទ្ធិរដ្ឋប្បវេណីពេញលេញពុំដែលទទួលទណ្ឌកម្មមានកំរិតធ្ងន់ពីតុលាការឡើយ ។ លើសពីនេះទៅទៀត សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់នោះ ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្មដែលបានបំរើការយ៉ាងតិច ៥ឆ្នាំ ឬ ឥស្សរជន ពុំមែនជាមន្ត្រីរាជការដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ តែមានបទពិសោធន៍គ្រប់គ្រាន់ និង ជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានថិរៈវេលាពីរឆ្នាំ ហើយថិរវេលានេះអាចបន្តជាថ្មីទៀតបាន ។

ក្នុងការបំពេញអាណត្តិរបស់ខ្លួន សមាជិកក្រុមប្រឹក្សាភិបាលពុំទទួលការខុសត្រូវផ្ទាល់ខ្លួនម្នាក់ៗ ឬការទទួលខុសត្រូវរួមគ្នាទេ ។ ក្នុងករណីដែលសមាជិកណាម្នាក់មានកំហុសធ្ងន់ធ្ងរ សមាជិករូបនោះអាចត្រូវដកចេញពីមុខងាររបស់ខ្លួនគ្រប់ពេលវេលាដោយអនុក្រឹត្យ ។

**មាត្រា១០ :** ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាមនៃ **រ.ឧ.ស.ត** នឹងដើម្បីបំពេញ ឬ អនុញ្ញាតលិខិត និងឯកសារគ្រប់ជំពូក ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមាននាទី ÷

១) ផ្តល់ការយល់ព្រម លើគំរោងសហគ្រាស ដូចមានចែងនៅក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ ។

២) វាយតំលៃរៀងរាល់ពេលវេលា ដែលបានកំណត់ទុកមុនរួចហើយនូវលទ្ធផលដែលបានគ្រោងទុក ហើយចាត់វិធានការដើម្បីកែសំរួលអោយស្របតាមសភាពការណ៍ ។

៣) ផ្តល់ការយល់ព្រមលើតុល្យការនឹងគណនីប្រចាំឆ្នាំ ព្រមទាំងលើរបាយការណ៍សកម្មភាពរបស់សហគ្រាស ។

៤) សំរេចតាមសំណើ នៃអគ្គនាយកនូវរចនាសម្ព័ន្ធ នឹងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្សសំរាប់បុគ្គលិក ដោយគោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥) ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញា ដែល **រ.ឧ.ស.ត** ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទ ដូចមានគ្រោងក្នុងបទបញ្ញាជាធរមានស្តីពីកិច្ចសន្យា និងអនុសញ្ញា ដែលចុះដោយសហគ្រាសសាធារណៈ ។

៦) អនុញ្ញាតអោយលក់ ទិញ ជួញដូរ អចលនទ្រព្យគ្រប់ប្រភេទ ឬភាគហ៊ុនព្រម ទាំងអនុញ្ញាតការខ្ចីបុលកំឡុងកាល មធ្យម ឬ វែង ដោយ **រ.ឧ.ស.ត** ស្របតាមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ។

៧) សំរេចបង្កើតបើក បិទ ការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែង តាមការវិនិច្ឆ័យរបស់ខ្លួន ។

**មាត្រា ១១ :** ក្រុមប្រឹក្សាភិបាលបើកប្រជុំរាល់ៗវេលា អាស្រ័យតាមអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិក ដែលមានចំនួនបួននាក់យ៉ាងតិចក្នុងបណ្តាសមាជិកទាំងអស់ ។ ទោះយ៉ាងណាក៏ដោយ កិច្ចប្រជុំត្រូវធ្វើឡើងយ៉ាងតិចម្តងក្នុងរយៈពេលបីខែ។

ប្រធានដែលជាប់ធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ ក្នុងបណ្តាសមាជិកក្រុមប្រឹក្សាភិបាល សំរាប់បំពេញភារៈកិច្ចជំនួយប្រធានជាបណ្តោះអាសន្ន ។

ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយដែលចូលក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និង «មន្ត្រីត្រួតពិនិត្យរដ្ឋ» អោយបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តបាន លុះត្រាតែចំនួន សមាជិកវត្តមាន ក្នុង សម័យប្រជុំនោះមានចំនួនយ៉ាងតិចពាក់កណ្តាលនៃបណ្តាសមាជិកទាំងអស់ ។ បើសិនជាចំនួនកូរ៉ុមមិនបានគ្រប់ទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំជាថ្មីម្តងទៀត ក្នុងរយៈពេល ១៥ ថ្ងៃក្រោយ ដើម្បីពិភាក្សាសំរេចឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ មិន ទាមទារកូរ៉ុមទេ ។

សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការ អនុម័តដោយសម្លេងភាគច្រើន នៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។ បើសិនការចែកសម្លេងមានចំនួនស្មើ ពុំអាចដាច់ស្រេចបានសម្លេងប្រធានមានអាទិភាពលើសម្លេងសមាជិកដទៃទៀត ។

**មាត្រា ១២ :** សេចក្តីសំរេចនៃក្រុមប្រឹក្សាភិអាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅអាជ្ញាធរអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង «មន្ត្រីត្រួតពិនិត្យរដ្ឋ» និងគោលដៅ ដទៃទៀត ដែលមានចែងក្នុងមាត្រា២៥ ខាងក្រោម ក្នុងរវាង១៥ថ្ងៃ យ៉ាងយូរ ចាប់រាប់ពីថ្ងៃប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកក្រោយហើយត្រូវចំឡងចូលបញ្ជី ដែលមានលេខរៀងទំព័រជាហូរហែ និងមានហត្ថលេខាចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើម ត្រូវមានចុះ

ហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុម ប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

**មាត្រា ១៣ :** អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងប្រក្រតីនៃ **រ.ឧ.ស.គ** ។ អគ្គនាយកនេះ ត្រូវតែងតាំងសំរាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើនៃអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ១៤ :** ក្រុមប្រឹក្សាភិបាលប្រគល់ជូនអគ្គនាយក នូវអំណាចចាំបាច់សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយក ÷

១–ជាអ្នករៀបចំសំណុំរឿងទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល និងជាអ្នកចាត់ចែងការអនុវត្តន៍រាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់ពេលនិមួយៗ អគ្គនាយកត្រូវរាយការណ៍ ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **រ.ឧ.ស.គ** ។

២–ទទួលបន្ទុកដឹកនាំ **រ.ឧ.ស.គ** ផ្នែកបច្ចេកទេស រដ្ឋបាល និង ហិរញ្ញវត្ថុ ។

៣–តំណាងសហគ្រាសចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាមស៊ីវិលរដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤–មានសិទ្ធិជ្រើសរើសតែងតាំងដកហូតតំណែង ឬ បញ្ឈប់ពីការងារមានសិទ្ធិបញ្ជាត្រួតត្រា នូវភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបដែលជានិយោជិករបស់ **រ.ឧ.ស.គ** ដោយគោរពតាមបទបញ្ញត្តិលក្ខន្តិកៈបុគ្គលិក តាមច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥–មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬ ទាំងអស់ ព្រមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅអោយមន្ត្រី ដែលធ្វើការក្រោមឱវាទខ្លួន ស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦–ជាសរុបអគ្គនាយកជាអ្នកអនុវត្តនូវគ្រប់ភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់អោយ ។

**មាត្រា ១៥ :** លាភការរបស់អគ្គនាយក និងប្រាក់បំណាច់សំរាប់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអាជ្ញាធរអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៦ :** ការចុះ និងការអនុវត្តកិច្ចសន្យាដោយ **រ.ឧ.ស.គ** ត្រូវគោរពតាមបែបបទ និង និតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៧ :** **រ.ឧ.ស.គ** កាន់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀលស្រប តាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាន នៃគណនេយ្យ ដែលគេទទួលស្គាល់ជាទូទៅ ។ រយៈការិយបរិច្ឆេទ គណនេយ្យ ចាប់ផ្តើមពីថ្ងៃទី ១មករា ហើយ បញ្ចប់នៅថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រង ត្រូវកំណត់ទូទាត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ ៣០ ខែ មិនា នៃឆ្នាំបន្ទាប់ឆ្នាំបិទការិយបរិច្ឆេទ ឈរលើរបាយការណ៍ នៃគណនេយ្យករជំនាញម្នាក់ ដែល មានមុខងារជាស្នងគណនី ។

តុល្យការគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ ព្រមអំពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកំឡុងវេលាមិនលើសពី ១៥ ថ្ងៃរាប់ពីថ្ងៃដែលក្រុម ប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះក៏ត្រូវបញ្ជូន ទៅអាជ្ញាធរអាណាព្យាបាលផងដែរ ដើម្បីសុំមតិ ទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈ នៃសហគ្រាសសាធារណៈ ។

**មាត្រា ១៨ :** ស្នងការគណនីត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលសំរាប់អាណត្តិ ២ឆ្នាំចិរ វេលានេះអាចបន្តទៀតបាន ។ ប្រាក់បំណាច់សំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលហើយ ត្រូវចាត់ទុកជាចំណាយអាជីវកម្មរបស់ **រ.ឧ.ស.គ** ។

ស្នងការគណនីត្រូវធ្វើរបាយការណ៍មួយ ដើម្បីបញ្ជាក់ថា គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុ និងបេតិកភ័ណ្ឌរបស់ **រ.ឧ.ស.គ** ។

នៅគ្រប់ពេលវេលា ស្នងការគណនី អាចធ្វើការផែកឆេរ និងការត្រួតពិនិត្យ ដែលខ្លួនយល់ថា ចាំបាច់គួរតែត្រូវពិនិត្យ ថែមទាំងអាចទារឯកសារ និងបញ្ជីគណនេយ្យគ្រប់យ៉ាងសំរាប់ធ្វើការត្រួតពិនិត្យ ។ បើការពិនិត្យស្រាវជ្រាវនេះបង្ហាញអោយឃើញភាពមិនត្រឹមត្រូវណាមួយស្នងការគណនីត្រូវរាយការណ៍ភ្លាមជូនប្រធានក្រុមប្រឹក្សាភិបាល ។

ស្នងការគណនីអាចចូលប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមសេចក្តីអញ្ជើញនៃប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៩ :** រៀងរាល់ឆ្នាំមុនថ្ងៃ ១ ខែ តុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងសហគ្រាសនេះត្រូវបញ្ជាក់នូវ ÷

១– កម្មវិធីវិនិយោគ ព្រមទាំង ហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ

២– ថវិកាសំរាប់ដំណើរការនៃសហគ្រាស

៣– តម្លៃលក់ទឹក និងតម្លៃលក់សេវាកម្មផ្សេងៗរបស់ **រ.ទ.ស.ភ** ទៅអតិថិជន ដើម្បីសហគ្រាសអាចមានលទ្ធភាពទប់ទល់ នឹងសោហ៊ុយដែលមានគិតបញ្ចូលនូវប្រាក់រំលស់ទុនវិនិយោគ និង អាចធានាសមតាហិរញ្ញវត្ថុរបស់ខ្លួនបាន

៤– លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **រ.ទ.ស.ភ** ។

៥– វិភាគទានទាំងឡាយដែលរដ្ឋអាចផ្តល់ជូន **រ.ទ.ស.ភ** ដើម្បីជ្រោមជ្រែងការបង់ខាតចំពោះសេវាសាធារណៈ ដែលសហគ្រាសបានផ្តល់សំរាប់បំរើអត្ថប្រយោជន៍របស់ពលរដ្ឋ ។

**មាត្រា ២០ :** ធនធាននៃ **រ.ទ.ស.ភ** ជាអាទិ៍មាន ÷

– ប្រាក់ដើមទុនដែលរដ្ឋផ្តល់អោយ

– វិភាគទាន ឬ ប្រាក់ឧបត្ថម្ភដែលបានមកពីរដ្ឋ និងសមូហភាពសាធារណៈផ្សេងៗ

-ប្រាក់ឧបត្ថម្ភដែលបានមកពីវិភាគទាន ឬ អំណោយ ក្នើមរតកឹងកជន ដោយមានការ ទទួលព្រមព្រៀងជាបឋមពីក្រុមប្រឹក្សាភិបាល ។

-ប្រាក់ខ្ចីបុល

-ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពសហគ្រាស

-ប្រាក់បានមកពីការលក់ ឬ ផ្ទេរទ្រព្យចលនវត្ថុ ឬ អចលនវត្ថុ

**មាត្រា២១ :** ចំណាយនៃ **ទ.ឧ.ស.គ** ជារួមមាន :

-ចំណាយប្រក្រតី សំរាប់ដំណើរការ

-ចំណាយវិនិយោគ

-សំណងបំណុល

-សោហ៊ុយផ្សេងៗដែល **ទ.ឧ.ស.គ** ត្រូវចំណាយដើម្បីបំពេញ បេសកកម្មរបស់ខ្លួន ។

**មាត្រា ២២ :** **ទ.ឧ.ស.គ** អាចមានគណនីចរន្ត ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣ :** ក្នុងរយៈពេល៥ឆ្នាំ ឬ លើសពីនេះ បើមានការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រាក់ចំណេញដែល **ទ.ឧ.ស.គ** ទទួលបានក្រោយពីការទូទាត់ស្របតាមវិធាន ។

**មាត្រា ២៣ :** ក្នុងរយៈពេល៥ឆ្នាំ ឬ លើសពីនេះ បើមានការសំរេចពីរដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រាក់ចំណេញដែល **ទ.ឧ.ស.គ** ទទួលបានក្រោយពីការទូទាត់ស្របតាមវិធានការគណនេយ្យដែលគេ ទទួលស្គាល់ជាទូទៅ ត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងមួយ ដើម្បីពង្រឹងលទ្ធភាពហិរញ្ញវត្ថុរបស់ **ទ.ឧ.ស.គ** ។

មាត្រា ២៤ : ការខ្ចីបុលកំឡុងកាលមធ្យម ឬ វែងដោយ ទ.ឧ.ស.គ សំរាប់ប្រើប្រាស់លើចំណាយវិនិយោគ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

## មាត្រា២៥

**មាត្រា ២៥ :** ១៥ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល **រ.ឧ.ស.ត** ត្រូវផ្ញើជូនរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ÷

- កំណត់ហេតុ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនីមួយៗ
- គំរោងសហគ្រាស ដូចមានចែងក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ
- របាយការណ៍ស្តីពីសកម្មភាពតុល្យការ និង គណនីគ្រប់គ្រងទាំងឡាយនៃ **រ.ឧ.ស.ត**
- របាយការណ៍ស្តីពីការត្រួតពិនិត្យរបស់ស្នងការគណនី

**មាត្រា ២៦ :** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើរដ្ឋាភិបាលតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់អម **រ.ឧ.ស.ត** ។ មន្ត្រីរូបនេះចូលរួមគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចទាំងឡាយដែលមានក្នុងរបៀបវារៈ តែពុំមានសម្លេងឆ្នោតទេ ។ «មន្ត្រីត្រួតពិនិត្យរដ្ឋ» បំពេញបេសកកម្មរបស់ខ្លួនអនុលោមតាមបទបញ្ញត្តិ នៃមាត្រា២០ ទៅ២៥ នៃព្រះរាជក្រម លេខ ០៦៩៦/០៣ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២៧ :** **រ.ឧ.ស.ត** មានសិទ្ធិផ្អាក ឬ ផ្តាច់ការផ្តល់ទឹក ឬ សេវាដទៃទៀត ចំពោះអតិថិជនឯកជន ឬ អង្គភាពសាធារណៈណាមួយ ដែលមិនបង់ថ្លៃទឹកទៅអោយ **រ.ឧ.ស.ត** ក្នុងរយៈវេលាដែលបាន កំណត់ក្នុងកិច្ចសន្យាជាវទឹក ។

## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ២៨ :** ការទំនាក់ទំនងរវាង **រ.ឧ.ស.ត** និងអតិថិជនព្រមទាំងអំពើល្មើសច្បាប់ទាំងឡាយពីសំណាក់ អតិថិជន ដែលប៉ះពាល់ដល់សហគ្រាស ជាពិសេសការបំបាត់ចំនួនទឹកដែលត្រូវបានប្រើប្រាស់ ការបំផ្លិចបំផ្លាញ ឬ ការកេងប្រវ័ញ្ចវត្ថុ

ដែលជាកម្មសិទ្ធិរបស់ **រ.ឧ.ស.ត** ការលួចតបណ្តាញទឹកដោយគ្មានការអនុញ្ញាត ។ល។ ត្រូវស្ថិតនៅក្រោមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ។

**មាត្រា ២៩ :** សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

បានបង្គំទូលថ្វាយ និងជំរាបជូន នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២ ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

* * *

# ២_សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

**សេចក្តីសំរេច លេខ ៤៩ សសរ**

**ស្តីពីការជូនបំណ្ណសរសើរ**

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤